ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងនៅកម្ពុជា ឆ្នាំ២០១៦

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងចំពោះសាធារណជន កម្មករនិយោជិត អង្គការវិជ្ជាជីវៈ និយោជក អង្គការជាតិ និងអន្តរជាតិទាំងអស់ឱ្យបានជ្រាបថា ក្នុងឆ្នាំ២០១៥ នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបន្តពង្រឹងយន្តការ នីតិវិធី និងការយល់ដឹងអំពីលក្ខណវិនិច្ឆ័យនៃការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងនៅកម្ពុជា ដោយបានរៀបចំសិក្ខាសាលាត្រីភាគី ដើម្បីពង្រឹងសមត្ថភាពដល់ភាគីកម្មករនិយោជិត និយោជក និងរាជរដ្ឋាភិបាល ហើយបានឯកភាពគ្នានឹងយកបម្រែបម្រួលនៃលក្ខណវិនិច្ឆ័យទាំង៧ ធៀបជាមួយនឹងប្រាក់ឈ្នួលអប្បបរមាឆ្នាំ២០១៥ ជាមូលដ្ឋានសម្រាប់កំណត់ប្រាក់ឈ្នួលអប្បបរមាឆ្នាំ២០១៦។

ទន្ទឹមនឹងនេះ គណៈកម្មការប្រឹក្សាការងារក៏បានបន្តបង្កើតឱ្យមានក្រុមការងារបច្ចេកទេសត្រីភាគីដែលមានតំណាងភាគីនិយោជកចំនួន១៦រូប តំណាងភាគីកម្មករនិយោជិតចំនួន១៦រូប និងតំណាងភាគីរាជរដ្ឋាភិបាលចំនួន១៦រូប ដើម្បីពិភាក្សាលម្អិតអំពីបម្រែបម្រួលលក្ខណវិនិច្ឆ័យទាំង៧ ក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងឆ្នាំ២០១៦។ បន្ទាប់ពីកិច្ចប្រជុំចំនួន៨ថ្ងៃ ចាប់ពីថ្ងៃទី២៨ ខែកញ្ញា ដល់យប់ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៥ ស្មើនឹង១៥លើក ក្រុមការងារបច្ចេកទេសត្រីភាគីបានបោះឆ្នោតជាសម្ងាត់ ដោយទទួលបានលទ្ធផលគាំទ្រតួលេខ ១៣៣ដុល្លារអាមេរិក ចំនួន១៦សំឡេង តួលេខ១៣៥ដុល្លារអាមេរិក ចំនួន១៥សំឡេង និងតួលេខ១៦០ដុល្លារអាមេរិក ចំនួន១៣សំឡេង លើសំឡេងសរុប៤៤ ដើម្បីដាក់ជូនគណៈកម្មការប្រឹក្សាការងារពិនិត្យពិភាក្សាបន្ត។

កាលពីព្រឹកថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ គណៈកម្មការប្រឹក្សាការងារបានបើកកិច្ចប្រជុំការងារអាណត្តិទី៨ លើកទី១៣ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបន្តពិនិត្យនិងពិភាក្សាលើលទ្ធផលរបស់ក្រុមការងារបច្ចេកទេសត្រីភាគី និងធ្វើការពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ឆ្នាំ២០១៦ ប៉ុន្តែមិនទទួលបានការគាំទ្រជាឯកច្ឆ័ន្ទលើតួលេខណាមួយឡើយ ព្រោះភាគីនិយោជកនៅរក្សាជំហរ ១៣៣ដុល្លារអាមេរិក ហើយភាគីសហជីពនៅតែរក្សាគោលជំហរ ១៦០ដុល្លារអាមេរិកដដែល។ ដោយគោរពទៅតាមគោលការណ៍ និងយន្តការដែលបានឯកភាពគ្នាដោយត្រីភាគី គណៈកម្មការប្រឹក្សាការងារបានបោះឆ្នោតជាសម្ងាត់លើតួលេខ៣ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

-តួលេខចំនួន ១៣៣ ដុល្លារអាមេរិក ទទួលបានសំឡេងឆ្នោត ០ លើ ២៨
-តួលេខចំនួន ១៣៥ ដុល្លារអាមេរិក ទទួលបានសំឡេងឆ្នោត ២៤ លើ ២៨
-តួលេខចំនួន ១៦០ ដុល្លារអាមេរិក ទទួលបានសំឡេងឆ្នោត ២ លើ ២៨
-និងសំឡេងមិនបានការចំនួន ២ លើ២៨ សំឡេង



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

ដូច្នេះ គណៈកម្មការប្រឹក្សាការងារបានស្នើតួលេខចំនួន ១៣៥ (មួយរយសាមសិបប្រាំ) ដុល្លារអាមេរិក ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើការពិនិត្យសម្រេចលើប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ឆ្នាំ២០១៦។

យោងតាមរបាយការណ៍របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលតែងតែយកចិត្តទុកដាក់អំពីសុខុមាលភាព និងជីវភាពរស់នៅសមរម្យរបស់កម្មករនិយោជិត និងផលិតភាពរបស់រោងចក្រ សហគ្រាស គ្រឹះស្ថាន បានសម្រេចបន្ថែមទឹកប្រាក់ចំនួន៥(ប្រាំ)ដុល្លារអាមេរិកលើទឹកប្រាក់ចំនួន១៣៥ (មួយរយសាមសិបប្រាំ) ដុល្លារអាមេរិក។ ដូច្នេះ ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ឆ្នាំ២០១៦ មានចំនួន១៤០(មួយរយសែសិប) ដុល្លារអាមេរិកក្នុងមួយខែ ដោយគិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ តទៅ។

ទន្ទឹមនឹងនេះ ប្រាក់អត្ថប្រយោជន៍ផ្សេងទៀត ដែលកម្មករនិយោជិតធ្លាប់ទទួលបានកន្លងមក ត្រូវបានរក្សាទុកដដែល មានដូចជាប្រាក់សោហ៊ុយធ្វើដំណើរ និងស្នាក់នៅចំនួន៧ដុល្លារអាមេរិកក្នុងមួយខែ ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន១០ដុល្លារអាមេរិកក្នុងមួយខែ ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងដោយស្ម័គ្រចិត្តចំនួន២០០០រៀលក្នុងមួយថ្ងៃ ឬទទួលបានបាយមួយពេលដោយឥតគិតថ្លៃ និងប្រាក់រង្វាន់អតីតភាពការងារចំនួន២ដុល្លារអាមេរិក ដល់ ១១ដុល្លារអាមេរិកក្នុងមួយខែ សម្រាប់កម្មករនិយោជិតដែលបានធ្វើការចាប់ពីឆ្នាំទី២ ដល់ឆ្នាំទី១១។ ដូច្នេះ ជាមធ្យមកម្មករនិយោជិតម្នាក់នឹងទទួលបានប្រាក់បៀវត្សយ៉ាងតិចចំនួន១៥៧ ដុល្លារអាមេរិកដល់ ១៦៨ដុល្លារអាមេរិកក្នុងមួយខែ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានសម្រេចផ្តល់ប្រាក់បន្ថែមចំនួន៥ដុល្លារអាមេរិក សម្រាប់ការដំឡើងប្រាក់ឈ្នួលអប្បបរមាឆ្នាំ២០១៦ នេះ ដែលធ្វើឱ្យស្ថានភាពជីវភាពរបស់បងប្អូនកម្មករនិយោជិត កាន់តែមានភាពល្អប្រសើរឡើងជាងមុន ហើយក៏ជាកត្តាដ៏សំខាន់ក្នុងការជំរុញផលិតភាពផងដែរ។

ក្រសួងក៏សូមថ្លែងអំណរគុណដល់អង្គការ ILO ដែលបានផ្តល់នូវកិច្ចសហការដ៏ជិតស្និទ្ធដល់ក្រសួងក្នុងការពង្រឹងយន្តការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងនៅកម្ពុជា។ ជាមួយគ្នានេះដែរ ក្រសួងក៏សូមថ្លែងអំណរគុណដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ដែលបានចូលរួមយ៉ាងសកម្មក្នុងការដោះស្រាយបញ្ហាប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិត ផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ឆ្នាំ២០១៦។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន កម្មករនិយោជិត អង្គការវិជ្ជាជីវៈគ្រប់ជាន់ថ្នាក់ និយោជក អង្គការជាតិ និងអន្តរជាតិ មេត្តាជ្រាបជាព័ត៌មានតាមការគួរ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥

ព្រះរាជាណាចក្រកម្ពុជា * ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ *